Open Development Cambodia
www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 224 782
contact@opendevcam.net

# សិក្ខាសាលាស្តីពី ការប្រមូលទិន្នន័យតាមទូរស័ព្ទដៃជាមួយនឹងកម្មវិធី Kobo Toolbox

## សេចក្តីផ្តើម

បច្ចេកវិទ្យាទូរស័ព្ទចល័ត បានធ្វើការប្រមូលទិន្នន័យកាន់តែមានភាពងាយស្រួលជាងមុន ដោយយើងមិនចាំបាច់ត្រូវយកក្រដាស ប៊ិច កាមេរ៉ា និងជីភីអេស តាមខ្លួនដើម្បីធ្វើការស្ទង់មតិទៀតទេ។ ទូរស័ព្ទឆ្លាតវៃរបស់អ្នកអាចដំណើរការជំនួសវត្ថុទាំងនោះបាន និងធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការស្ទង់មតិ និងការវាយតំលៃ។ ដោយមើលឃើញពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទូរស័ព្ទដៃក្នុងការប្រមូលទិន្នន័យ អង្គការទិន្នន័យអំពីការអភិវឌ្ឍ ហៅកាត់ថាអូឌីស៊ី មានសេចក្តីសោមនស្សរីករាយក្នុងការប្រកាសបើកសិក្ខាសាលាស្តីពី "ការប្រមូលទិន្នន័យតាមទូរស័ព្ទដៃជាមួយកម្មវិធី Kobo Toolbox"។ សិក្ខាសាលាសានេះនឹងផ្តោតលើ៖

- គោលការណ៍ និងរបៀបប្រើប្រាស់កម្មវិធី Kobo Toolbox ដែលជាបច្ចេកវិទ្យាដ៏សមស្រប និងងាយស្រួលសម្រាប់ទូរស័ព្ទដៃក្នុងការរៀបចំកម្រងសំណួរ ប្រមូលទិន្នន័យ និងគ្រប់គ្រងទិន្នន័យដែលមានគុណភាពខ្ពស់។
- ការអនុវត្តកម្មវិធី Kobo Toolbox ជាក់ស្តែង ក្នុងវិស័យគណនេយ្យភាពសង្គម ដើម្បីធ្វើឱ្យសេវាសាធារណៈកាន់តែប្រសើរឡើង ។

វគ្គសិក្សានេះ គាំទ្រថវិកាដោយ កម្មវិធីរបស់ប្រទេសស៊ុយអែតសម្រាប់វិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន នៅក្នុងតំបន់កំពុងអភិវឌ្ឍន៍ (SPIDER)




#43, Street 208, Sangkat Boeung Rain, Khan Daun Penh
Phnom Penh, Cambodia.

## អំពីសិក្ខាសាលា៖

- ទីតាំង៖ មជ្ឈមណ្ឌល ដាយកូនៀ (Phnom Penh Ecumenical Diakonia Centre)
- កាលបរិច្ឆេទ៖ **ចាប់ពីថ្ងៃទី ១៦ ដល់ ថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៩**
- ថ្លៃចូលរួម៖ **ឥតបង់ថ្លៃ**
- អត្ថប្រយោជន៍៖ សម្ភារៈសិក្សា កម្មវិធី  អ៊ិនធើណេត អាហារសម្រន់ និងអាហារថ្ងៃត្រង់
- មេរៀនសិក្សា៖ ភាសាខ្មែរ និងអង់គ្លេស
- តម្រូវការ៖ អ្នកចូលរួមត្រូវមាន កុំព្យូរយួរដៃ ចំណេះដឹងក្នុងការប្រើប្រាស់កុំព្យូទ័រកម្រិតមូលដ្ឋាន ចំណេះដឹងក្នុងការរៀបចំកម្រងសំណួរកម្រិតមូលដ្ឋាន និងភាសាអង់គ្លេសកម្រិតមូលដ្ឋាន (អាចយល់ពីពាក្យអង់គ្លេសទូទៅបាន)
- សម្រាប់ការចុះឈ្មោះ ៖ https://forms.gle/mrKZXQcjQHPdZsAK7
- ថ្ងៃផុតកំណត់ចុះឈ្មោះ៖ **ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៩**
- ថ្ងៃប្រកាសឈ្មោះបេក្ខជន៖ **ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩**
- សូមទាក់ទងមកកាន់៖ កញ្ញា ឌុច សុធាវីន
    - សារអេឡិចត្រូនិក៖  sotheavin@opendevcam.net
    - លេខទូរស័ព្ទ៖ ០៩៣ ៧១៨ ៧២៤

## សិក្ខាសាលាវគ្គមុន




Open Development Cambodia
www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 224 782
contact@opendevcam.net

***អំពីអ្នករៀបចំ***

***អង្គការទិន្នន័យអំពីការអភិវឌ្ឍ*** *ហៅកាត់ថា**អូឌីស៊ី*** *គឺជាគេហទំព័របែប "ទិន្នន័យបើកទូលាយ"។ គេហទំព័រប្រភេទនេះ ជាគេហទំព័រដំបូងគេបង្អស់នៅតំបន់អាស៊ីអាគ្នេយ៍។ ចលនា "ទិន្នន័យបើកទូលាយ" គឺផ្អែកលើការសន្មត់ដ៏សាមញ្ញមួយថា ទិន្នន័យ ឬព័ត៌មានទាំងឡាយណា ដែលត្រូវបានប្រមូលផ្តុំសម្រាប់ផលប្រយោជន៍សាធារណៈ គួរតែដាក់ឱ្យប្រើប្រាស់បានជាសាធារណៈ ពោលគឺដោយគ្មានការដាក់កំហិតឡើយ។ ព័ត៌មានឬ "ទិន្នន័យ" ទាក់ទងនឹងវិស័យសាធារណៈគួរផ្តល់ឱ្យដោយសេរីដល់គ្រប់ៗគ្នា ដើម្បីប្រើ និងធ្វើការផ្សព្វផ្សាយជាសាធារណៈតាមបំណងប្រាថ្នារបស់អ្នកប្រើប្រាស់។ អង្គការអូឌីស៊ីមិនធ្វើការលើកស្ទួយ ឬផ្សព្វផ្សាយទស្សនៈ របៀបវារៈ ឬការលម្អៀងណាមួយ ក្រៅពីការផ្តល់ព័ត៌មានជាសត្យានុម័តអំពីប្រទេសកម្ពុជា និងការអភិវឌ្ឍរបស់ប្រទេសនោះឡើយ។*